សុន្ទរកថារបស់ **លោក តាស៊ីយ៉ា ម៉ាជីដា** ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

២៧ មិនា ២០១២

**សូមគោរព បណ្ឌិត ប៉ែន សេដ្ឋារិន តំណាងសមាគមវប្បធម៌អាស៊ីអាគ្នេយ៍ (CAPSEA)!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំា នសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ CAPSEA ដើម្បីគាំទ្រគម្រោងអក្ខរកម្ម។

ជំនួយឧបត្ថម្ភអាទិភាពមួយក្នុងចំណោមជំនួយឧបត្ថម្ភរបស់ជប៉ុនចំពោះព្រះរាជាណាចក្រកម្ពុជាគឺការគាំទ្រពង្រឹងវិស័យអប់រំ។ ជាមួយគ្នានេះ ប្រទេសជប៉ុនបាន និងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភគាំទ្រដល់វិស័យនេះទាំងផ្នែកសម្ភារៈ និងបច្ចេកទេស។

ជំនួយដែលមានទឹកប្រាក់សរុបចំនួន **១៧,៥៧០ដុល្លាអាមេរិក** នេះត្រូវបានផ្តល់ជូនដើម្បីគាំទ្រដល់គម្រោងអក្ខរកម្មនៅតំបន់ជុំវិញរាជធានីភ្នំពេញ។

តាមរយៈការស្នើសុំរបស់CAPSEA និងការអង្កេតដល់ទីកន្លែងដែលធ្វើឡើងដោយបុគ្គលិកស្ថានទូតយើងទទួលស្គាល់នូវតម្រូវការបន្ទាន់នៃសៀវភៅអំនានភាសាខ្មែរដើម្បីពង្រឹងការអប់រំអក្ខរកម្មនៅថ្នាក់អក្ខរកម្មមួយ និងសាលាបឋមសិក្សាចំនួន១៩ក្នុងខេត្ត៤ដែលនៅជុំវិញរាជធានីភ្នំពេញ។

តាមរយៈគម្រោងនេះ កុមារប្រមាណ៣,០០០នាក់នឹងរីករាយក្នុងការរៀនអាន និងសរសេរជាមួយសៀវភៅអំនានភាសាខ្មែរដែលមានពណ៌ចម្រុះ។ ជាងនេះទៅទៀត បណ្ណាល័យចល័តរបស់ CAPSEA គ្រោងនឹងទៅដល់ភូមិផ្សេងៗជារៀងរាល់សប្តាហ៍ដែលអាចឲ្យសិស្សានុសិស្ស និងប្រជាជនក្នុងភូមិអានសៀវភៅផ្សេងៗដែលរួមទាំងសៀវភៅរូបភាពដែលបកប្រែពីភាសាជប៉ុនដែលយើងរំពឹងថានឹងផ្តល់នូវប្រសិទ្ធភាពកាន់តែប្រសើរឡើងក្នុងការលើកទឹកចិត្តពួកគេឲ្យចេះអក្សរ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការសម្រេចឲ្យបាននូវគោលដៅជាតិមួយក្នុងចំណោមគោលដៅនៃ “ការអប់រំសម្រាប់ទាំងអស់គ្នា ” គឺការសម្រេចឲ្យបាននូវកម្រិតចេះអក្សរសម្រាប់មនុស្សពេញវ័យឲ្យបាន៥០%នៅមុនឆ្នាំ២០១៥ បើធៀបនឹងអត្រានៅឆ្នាំ២០០៣។ ជាចុងក្រោយនេះ ខ្ញុំស ង្ឃឹមថា ជំនួយឧបត្ថម្ភសម្រាប់គម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនង មិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណ!